Info
Note
2

# ការទប់ស្កាត់ទារុណកម្មនៅកម្ពុជា

ការផ្តល់សច្ចាប័ននៃពិធីសារបន្ថែមរបស់ប្រទេសកម្ពុជាលើអនុសញ្ញាប្រឆាំងទារុណកម្ម និង
ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ***(OPCAT)***

ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) ត្រូវបានអនុម័តដោយមហាសន្និបាតអ.ស.ប នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ហើយបានចូលជាធរមានក្នុងច្បាប់អន្តរជាតិ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។ OPCAT ផ្តល់យន្តការបង្ការបន្ថែម ដើម្បីថានាថា រដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៨៤ប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត មកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប បំពេញបាននូវការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីហាមប្រាមការធ្វើទារុណកម្មតាមគ្រប់រូបភាព។ យន្តការទាំងនេះ មានស្ថាប័នបន្ថែមស្របគ្នាចំនួនពីរ មួយជា ស្ថាប័នជាតិ ហើយមួយទៀតជាស្ថាប័នអន្តរជាតិ ៈ

- នៅថ្នាក់អន្តរជាតិ មានគណៈកម្មាធិការមួយ ដែលមានសមាសភាពអ្នកជំនាញការអន្តរជាតិ ចំនួនដប់រូប ដែលគេហៅថាអនុគណៈកម្មាធិការបង្ការ ដែលនឹងធ្វើទស្សនកិច្ចនៅតាមមន្ទីរឃុំឃាំងនានាលើទឹកដីនៃ រដ្ឋភាគី ដើម្បីបញ្ជាក់ថា ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្សេងទៀតមិនត្រូវបានអនុញ្ញាត។

- នៅថ្នាក់ជាតិ រដ្ឋភាគីនីមួយៗត្រូវបង្កើត យន្តការជាតិមួយឯករាជ្យ ដើម្បីបង្ការការធ្វើទារុណ កម្ម ដែលស្របគ្នាជាមួយអនុគណៈកម្មាធិការបង្ការ។ យន្តការជាតិនេះក៏នឹងត្រូវធ្វើទស្សនកិច្ចនៅតាមមន្ទីរ ឃុំឃាំងនានា ដើម្បីបញ្ជាក់ថាការធ្វើទារុណកម្ម និងការអនុវត្តន៍ស្រដៀងគ្នានេះ មិនត្រូវបានអនុញ្ញាត ឡើយ និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីហាមប្រាម និងបង្ការការធ្វើទារុណកម្ម។

កម្ពុជាបានក្លាយជាភាគីមួយនៃអនុសញ្ញាប្រឆាំងទារុណកម្ម នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញធានាការពារអនុសញ្ញានេះ ថាជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រា៣៨ ហាមប្រាមជា ពិសេស ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្សេងទៀត និងប្រកាសថា ចំលើយសារភាពដែលបានមកពីការ ធ្វើទារុណកម្ម មិនត្រូវយកជាភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពបានឡើយ។

*(Continued on page 2)*

# ការទប់ស្កាត់ទារុណកម្មនៅកម្ពុជា

ច្បាប់មួយដែលបញ្ចូលពិធីសារបន្ថែមនេះទៅក្នុងច្បាប់ជាតិ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ។ កម្ពុជាបានបំពេញសំណុំបែបបទសំរាប់ការផ្តល់សច្ចាប័ន នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ ហើយនឹងក្លាយជារដ្ឋភាគីមួយផ្លូវការនៃពិធីសារបន្ថែមនេះ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៧ ។ ពិធីសារនេះ ក៏នឹងត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញ មាត្រា៣១ ផងដែរ ។

ការទទួលយកពិធីសារបន្ថែមនេះរបស់កម្ពុជា តម្រូវឱ្យរដ្ឋាភិបាលចាត់វិធានការជាក់ស្តែងមួយចំនួន ដើម្បីអនុវត្តបទបញ្ញត្តិនៃពិធីសារបន្ថែមនេះ ។ ជំហានទីមួយ គឺត្រូវបង្កើតយន្តការជាតិមួយ ដើម្បីបង្ការទារុណកម្មនៅថ្នាក់ជាតិ ។ អនុលោមតាមពិធីសារនេះ យន្តការនេះត្រូវតែប្រព្រឹត្តទៅដោយឯករាជ្យ ហើយត្រូវតែស្របតាមគោលការណ៍ក្រុងប៉ារីសស្តីពីឋានៈនៃស្ថាប័នជាតិសិទ្ធិមនុស្ស ។ លើសពីនេះទៅទៀត បុគ្គលិកស្ថាប័ននេះ ត្រូវមានសមត្ថភាពវិជ្ជាជីវៈ និងឯករាជ្យពីការត្រួតត្រាខាងនយោបាយ និងត្រូវមានតុល្យភាពនៃភេទ ក៏ដូចជាតំណាងក្រុមជាតិពន្ធុ និងក្រុមជនភាគតិច ។ ពិធីសារនេះចែងពីសិទ្ធិ និងការទទួលខុសត្រូវជាក់លាក់មួយចំនួន ដែលយន្តការនេះត្រូវមានដើម្បីបំពេញអាណត្តិរបស់ខ្លួន ។ តាមលក្ខខណ្ឌនៃពិធីសារ យន្តការនេះត្រូវតែបង្កើតឡើងនៅថ្ងៃ ឬមុនថ្ងៃ ទី២៩ ខែមេសា ឆ្នាំ២០០៨ ។

អត្ថបទទាំងស្រុងនៃពិធីសារបន្ថែមនេះ ត្រូវបានដាក់ភ្ជាប់ជាមួយកំណត់ព័ត៌មាននេះ ។



រៀបរៀងដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា សំរាប់គោលបំណងកំណត់ព័ត៌មានប៉ុណ្ណោះ ។ នេះមិនមែនជាការបោះពុម្ពផ្សាយរបស់អងការសហប្រជាជាតិទេ

Office of the United Nations High Commissioner for Human Rights, House 10, Street 302, Phnom Penh, Cambodia
Telephone +855-23-993 590/91 Fax +855-23-212 579/87 cambodia@ohchr.org http://cambodia.ohchr.org